# សារលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ
# ក្នុងឱកាសរដូវអប់រំពិសេស ឆ្នាំ២០២៥
# *ចូរធ្វើដំណើររួមគ្នាក្នុងសេចក្តីសង្ឃឹម*

បងប្អូនជាទីស្រឡាញ់!

ក្នុងរដូវអប់រំពិសេស យើងចាប់ផ្តើមបូជនីយចររបស់យើង ពោរពេញដោយជំនឿ និងសេចក្តីសង្ឃឹម ដោយពិធីរោយផេះ។ ព្រះសហគមន៍ដែលជាមាតា និងជាបរមគ្រូ អញ្ជើញយើងឱ្យបើកចិត្តគំនិតចំពោះព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដើម្បីឱ្យយើងប្រារព្ធ ដោយអំណរសប្បាយ នូវជ័យជំនះរបស់ព្រះគ្រីស្តជាព្រះអម្ចាស់ លើអំពើបាប និងសេចក្តីស្លាប់ ដែលនាំសន្តប៉ូលឱ្យស្រែកឡើងថា៖ «ជ័យជម្នះបានបំបាត់មច្ចុរាជចោលហើយ! មច្ចុរាជអើយ តើជ័យជម្នះរបស់ឯងនៅឯណា? មច្ចុរាជអើយ តើអំណាចប្រហារជីវិតរបស់ឯងនៅឯណា?» (១ករ ១៥,៥៤-៥៥)។ តាមការពិត ព្រះយេស៊ូគ្រីស្ត ដែលគេបានឆ្កាង និងមានព្រះជន្មរស់ឡើងវិញ ជាស្នូលនៃជំនឿរបស់យើង និងជាបញ្ចាំនៃសេចក្តីសង្ឃឹមរបស់យើង ចំពោះព្រះបន្ទូលសន្យាដ៏អស្ចារ្យរបស់ព្រះបិតា ដែលទ្រង់បានបំពេញក្នុងអង្គព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ រួចស្រេចទៅហើយ ដោយប្រោសប្រទានជីវិតអស់កល្បជានិច្ច (យហ ១០,២៨; ១៧,៣)។

ក្នុងរដូវអប់រំពិសេសនៃអំឡុងឆ្នាំមហាករុណាទិគុណនេះ ខ្ញុំសូមស្នើសុំឱ្យរិះគិតពិចារណាខ្លះៗអំពី *ការរួមដំណើរជាមួយគ្នាក្នុងសេចក្តីសង្ឃឹម* មានអត្ថន័យអ្វីខ្លះ និងអំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដែលត្រាស់ហៅយើងទាំងអស់គ្នាទាំងបុគ្គលម្នាក់ៗ និងទាំងសហគមន៍ទាំងមូលឱ្យកែប្រែចិត្តគំនិត។

ជាដំបូង *ការធ្វើដំណើរ* ៖ ពាក្យស្លោកនៃឆ្នាំមហាករុណាទិគុណ "បូជនីយេសក៏នៃសេចក្តីសង្ឃឹម" សំដៅទៅលើការធ្វើដំណើរយ៉ាងយូរនៃប្រជាជនអ៊ីស្រាអែលឆ្ពោះទៅកាន់ទឹកដីសន្យា ដូចកណ្ឌគម្ពីរសេរីភាពរៀបរាប់។ ព្រះអម្ចាស់ ដែលស្រឡាញ់ប្រជារាស្ត្ររបស់ព្រះអង្គ និងមានព្រះហឫទ័យភក្តីចំពោះពួកគេជានិច្ច ទ្រង់ជាអ្នកសព្វព្រះហឫទ័យ និងជាអ្នកណែនាំប្រជាជនឱ្យដើរតាមផ្លូវដ៏លំបាកនេះ ដោយចេញពីទាសភាពទៅកាន់សេរីភាព។ ពិបាកនឹកគិតដល់ការចេញដំណើរក្នុងព្រះគម្ពីរ ដោយមិននឹកគិតដល់អស់បងប្អូនរបស់យើងសព្វថ្ងៃ ដែលរត់គេចខ្លួនពីស្ថានភាពដ៏វេទនា ពេញដោយហិង្សា ដើម្បីស្វែងរកជីវិតដ៏ប្រសើរជាង សម្រាប់ខ្លួនគេ និងអស់អ្នកដែលគេស្រឡាញ់ផងដែរ។ ហេតុនេះ ពេលដឹងខ្លួនថា យើងទាំងអស់គ្នាជាបូជនីយេសក៏ក្នុងជីវិតនេះ យើងចាប់ផ្តើមកែប្រែចិត្តគំនិត។ យើងម្នាក់ៗគួរឈប់ និងសួរខ្លួនថា តើរបៀបរស់នៅរបស់យើងឆ្លុះបញ្ចាំងបូជនីយចរនេះយ៉ាងដូចម្តេច? តើខ្ញុំនៅតែធ្វើដំណើរ ឬខ្ញុំឈរនៅស្ងៀមដោយមិនទៅមុខ ដូចជាស្ពឹកដៃស្ពឹកជើង ព្រោះតែខ្ញុំខ្លាច ខ្ញុំអស់សង្ឃឹម ខ្ញុំមិនចង់ចាកចេញពីជីវិតស្រណុកសុខស្រួលរបស់ខ្ញុំ? តើខ្ញុំស្វែងរកមធ្យោបាយផ្សេងៗ ដើម្បីលះបង់ឱកាសផ្សេងៗក្នុងការប្រព្រឹត្តបាប និងស្ថានភាពដែលបំផ្លាញ

សេចក្តីថ្លៃថ្នូររបស់ខ្ញុំឬទេ? បើយើងប្រៀបធៀបជីវិតប្រចាំថ្ងៃរបស់យើងជាមួយនឹងជនចំណាកស្រុក ឬជនបរទេសណាម្នាក់ បើយើងរៀនធ្វើជាមិត្តភក្តិ និងយល់អំពីពិសោធន៍របស់គេ ពេលនោះ ពិតជាការខិតខំដ៏ល្អក្នុងរដូវអប់រំពិសេស។ យើងនឹងរកឃើញអំពីអ្វីដែលព្រះជាម្ចាស់សុំពីយើង ទើបយើងអាចឈានទៅដល់ព្រះដំណាក់របស់ព្រះបិតាឱ្យបានទុកជាមុន។ ធ្វើដូច្នេះ យើងនឹងជួយបំភ្លឺមនសិការសម្រាប់យើងទាំងអស់គ្នាដែលកំពុងធ្វើដំណើរ។

ទីពីរ *រួមជាមួយគ្នា* ៖ ព្រះជាម្ចាស់ត្រាស់ហៅព្រះសហគមន៍ឱ្យដើររួមជាមួយគ្នា និងឱ្យបានទៅជាសហគមន៍។ ព្រះអង្គក៏ត្រាស់ហៅគ្រីស្តបរិស័ទឱ្យដើរជិតៗគ្នា ដោយមិនដែលធ្វើដំណើរតែម្នាក់ឯងឡើយ។ ព្រះវិញ្ញាណដ៏វិសុទ្ធជំរុញយើងឱ្យមិនគិតពីយើងតែប៉ុណ្ណោះទេ តែឱ្យយើងចាកចេញពីខ្លួនយើង ហើយនៅតែដើរតម្រង់ឆ្ពោះទៅព្រះជាម្ចាស់ និងបងប្អូនរបស់យើង។ ការធ្វើដំណើររួមគ្នាមានន័យថា ឱ្យយើងពង្រឹងឯកភាព ដែលចាក់ឫសក្នុងសេចក្តីថ្លៃថ្នូរ ជាឋានៈរួមរបស់យើង ជាបុត្រធីតារបស់ព្រះជាម្ចាស់ (កាឡ ៣,២៦-២៨)។ ត្រូវតែដើរជិតៗគ្នា ដោយមិនរុញ ឬដើរជាន់អ្នកដទៃ ដោយគ្មានការច្រណែន និងពុតត្បុត ដោយមិនឱ្យនរណាម្នាក់ដើរខាងក្រោយគេ ឬត្រូវគេបោះបង់ចោលឡើយ។ ចូរឱ្យយើងដើរក្នុងទិសដៅតែមួយ ឆ្ពោះទៅគោលដៅដូចៗគ្នា ដោយយកចិត្តទុកដាក់ចំពោះយើងម្នាក់ៗ ដោយមានចិត្តស្រឡាញ់ និងមានចិត្តអត់ធ្មត់ផង។

ក្នុងរដូវអប់រំពិសេសនេះ ព្រះជាម្ចាស់សូមឱ្យយើងរិះគិតពិចារណាថា ក្នុងជីវិតយើង ក្នុងក្រុមគ្រួសារយើង ក្នុងកន្លែងធ្វើការ និងក្នុងការចាយពេលវេលារបស់យើង តើយើងអាចដើររួមគ្នាជាមួយអ្នកដទៃ ស្តាប់គេ កុំឱ្យចាញ់ការល្បួងគិតតែពីខ្លួនឯង និងពីតម្រូវការរបស់យើងប៉ុណ្ណោះ។ ចំពោះព្រះភក្ត្ររបស់ព្រះអម្ចាស់ ចូរសួរខ្លួនឯងថា ក្នុងឋានៈជាលោកអភិបាល លោកបូជាចារ្យ អ្នកដែលថ្វាយខ្លួនទាំងស្រុង និងគ្រីស្តបរិស័ទធម្មតា តើយើងរួមសហការជាមួយអ្នកដទៃ ក្នុងការជួយបម្រើព្រះរាជ្យរបស់ព្រះជាម្ចាស់ឬទេ។ តើយើងបង្ហាញថា យើងជាអ្នកដែលចេះទទួលស្វាគមន៍អស់អ្នក ដែលនៅជិត ឬឆ្ងាយ ដោយប្រព្រឹត្តកិច្ចការពិតៗ។ តើយើងធ្វើឱ្យអ្នកដទៃមានអារម្មណ៍ថា ពួកគេជាសមាជិកនៃសហគមន៍ ឬយើងទុកពួកគេឱ្យនៅឆ្ងាយដាច់ពីយើង។ ពេលនោះ ជាការត្រាស់ហៅឱ្យកែប្រែចិត្តគំនិតជាលើកទីពីរ៖ ឱ្យរួមជាមួយគ្នា។

ទីបី ចូរឱ្យយើងធ្វើដំណើរ *ក្នុងសេចក្តីសង្ឃឹម* ស្របតាមព្រះបន្ទូលសន្យា៖ សូមឱ្យ "សេចក្តីសង្ឃឹមដែលមិនធ្វើឱ្យខកចិត្តឡើយ" (រម ៥,៥) ជាសារដ៏សំខាន់នៃឆ្នាំមហាករុណាទិគុណ អាចទៅជាគោលដៅនៃការធ្វើដំណើររបស់យើងឆ្ពោះទៅជ័យជម្នះនៃបុណ្យចម្លងក្នុងរដូវអប់រំពិសេសនេះ។ ដូចសម្តេចប៉ាបបេណេឌិកតូទី១៦ បានបង្រៀនយើងក្នុងសារលិខិត Spe Salvi មនុស្សលោកត្រូវការសេចក្តីស្រឡាញ់ ដែលគ្មានលក្ខខណ្ឌ។ ពួកគេត្រូវការដកពិសោធន៍អំពីសេចក្តីនេះឱ្យបានជាក់ច្បាស់ ដើម្បីអាចនិយាយថា៖ "ខ្ញុំជឿជាក់ថា ទោះបីសេចក្តីស្លាប់ក្តី ជីវិតក្តី ទេវទូតក្តី វត្ថុស័ក្តិសិទ្ធិនានាក្តី បច្ចុប្បន្នកាលក្តី អនាគតកាលក្តី អំណាចនានាក្តី អ្វីៗដែលនៅស្ថានលើក្តី នៅស្ថានក្រោមក្តី ឬអ្វីៗផ្សេងទៀតដែលព្រះជាម្ចាស់បង្កើតមកក្តី ក៏ពុំអាចបំបែកយើងចេញពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលព្រះអង្គបានសម្តែងឱ្យយើងឃើញក្នុងព្រះគ្រីស្តយេស៊ូ ជាអម្ចាស់នៃយើងបានឡើយ" (រម ៨,៣៨-៣៩)។ ព្រះគ្រីស្ត ដែលជាសេចក្តីសង្ឃឹមរបស់ខ្ញុំ ទ្រង់បានក្រោកឈរ! ព្រះអង្គមានព្រះជន្ម និងសោយរាជ្យនៅក្នុងសិរីរុងរឿង។ សេចក្តីស្លាប់បានក្លាយទៅជាជ័យជម្នះដ៏អស្ចារ្យ ហើយជំនឿ និងសេចក្តីសង្ឃឹមរបស់គ្រីស្តបរិស័ទស្ថិតក្នុងសេចក្តីនេះ៖ ព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ!

ការនេះ គឺជាការត្រាស់ហៅឱ្យកែប្រែចិត្តគំនិតជាលើកទីបី៖ ព្រះជាម្ចាស់ត្រាស់ហៅឱ្យសង្ឃឹម និងទុកចិត្តលើព្រះអង្គ និងក្នុងព្រះបន្ទូលសន្យាដ៏អស្ចារ្យអំពីជីវិតអស់កល្បជានិច្ច។ ចូរសួរខ្លួនឯង៖ តើខ្ញុំជឿជាក់ថា ព្រះជាម្ចាស់លើកលែងទោសអំពើបាបរបស់ខ្ញុំឬទេ? ឬក៏តើខ្ញុំរស់នៅបែបហាក់ដូចជាខ្ញុំអាចសង្គ្រោះខ្លួនឯងបាន? តើខ្ញុំប្រាថ្នាចង់បានការសង្គ្រោះ និងទូលអង្វរព្រះជាម្ចាស់ ដើម្បីឱ្យព្រះអង្គជួយសង្គ្រោះខ្ញុំឬទេ? តើខ្ញុំដកពិសោធន៍ពិតប្រាកដអំពីសេចក្តីសង្ឃឹម ដែលឱ្យខ្ញុំបកស្រាយហេតុការណ៍ផ្សេងៗនៃប្រវត្តិសាស្ត្រ និងជំរុញខ្ញុំឱ្យចូលរួមក្នុងការរកយុត្តិធម៌ និងកសាងសង្គមឱ្យបានទៅជាបងប្អូន ឱ្យខ្ញុំថែរក្សាលំនៅរួមរបស់យើង តាមរបៀបដែលគ្មាននរណាម្នាក់មានអារម្មណ៍ថា ត្រូវគេបោះបង់ចោលឬទេ?

បងប្អូនជាទីស្រឡាញ់! សូមអរព្រះគុណព្រះជាម្ចាស់ ដែលស្រឡាញ់យើងនៅក្នុងអង្គព្រះយេស៊ូគ្រីស្ត ព្រះអង្គដែលជួយទ្រទ្រង់យើងក្នុងសេចក្តីសង្ឃឹម ដែលមិនធ្វើឱ្យខកចិត្តឡើយ (រម ៥,៥)។ សេចក្តីសង្ឃឹមជាយុថ្កាដ៏ច្បាស់ និងដ៏រឹងមាំនៃព្រលឹងវិញ្ញាណ។ សេចក្តីសង្ឃឹមជួយព្រះសហគមន៍ឱ្យទៅមុខ និងអធិដ្ឋាន ដើម្បីឱ្យមនុស្សគ្រប់រូបទទួលការសង្គ្រោះ (១ ធម ២,៤) ដើម្បីឱ្យព្រះសហគមន៍រួមឯកភាពជាមួយព្រះគ្រីស្ត ជាកូនកំលោះ ក្នុងសិរីរុងរឿងនៃស្ថានបរមសុខ។ នេះគឺជាការអធិដ្ឋានរបស់សន្តីថេរេសានៅអាវីឡា៖ «អូ! ព្រលឹងវិញ្ញាណខ្ញុំម្ចាស់! ចូរសង្ឃឹម ចូរសង្ឃឹមអើយ! អ្នកមិនដែលដឹងថា ថ្ងៃណា ម៉ោងណាទេ។ ចូរប្រុងស្មារតី ដ្បិតអ្វីៗទាំងអស់ចេះតែកន្លងផុតទៅឱ្យបានលឿន ទោះជាអ្នកមិនចេះអត់ធ្មត់ធ្វើឱ្យអ្នកសង្ស័យអំពីអ្វីដែលជាក់ច្បាស់ និងធ្វើឱ្យពេលវេលាដ៏ខ្លីបានទៅជាយូរអង្វែង» (ការស្រែកឡើងនៃព្រលឹងវិញ្ញាណ ១៥,៣)។

សូមព្រះនាងព្រហ្មចារីនីម៉ារី ជាមាតានៃសេចក្តីសង្ឃឹម ទូលអង្វរព្រះជាម្ចាស់សម្រាប់យើង និងជួយកំដរយើងក្នុងរដូវអប់រំពិសេស។

ទីក្រុងរ៉ូម សន្តយ៉ូហាន ឡាតេរ៉ង់

ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥

បុណ្យរម្លឹកមរណសាក្សីសន្តប៉ូលមីគី និងសហការី

ហ្វ្រង់ស៊ីស្កូ